**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្ដាល**

**សាលាដំបូងខេត្តកណ្ដាល**

.សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៤ អកចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២

.ជំនុំជម្រះលេខ ៥៧៥ ជរ ចុះថ្ងៃទី ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០២២

.សាលក្រមលេខ ៩៨ (ប) ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៩៤ អក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២២ ដែលមាន៖

១- ជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និង បច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] ធី (រស់) ម្ដាយឈ្មោះ [redacted] សន (រស់) ទោសពីមុនគ្មាន។ (ឃាត់ខ្លួនថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០២២ និងចេញតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៦៥ ដកបឃខ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២២ )។

២-ជនជាប់ចោទឈ្មោះ [redacted] លាងហ៊ីម ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និង បច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះស្លូង គា(រស់)ម្ដាយឈ្មោះ [redacted] អែម (រស់) ទោសពីមុនគ្មាន។ (ឃាត់ខ្លួនថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ និង ចេញតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៦៧ ដកបឃខ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២២ )។

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២២ តាមមាត្រា ២៩ .មាត្រា ៣៥៣.មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ជនជាប់ចោទឈ្មោះ [redacted] សាម៉េន ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្ដាល និង បច្ចុប្បន្នខ្លួនគេចខ្លួនភូមិកោះខែល ឃុំកោះខែល ស្រុក



Scanned with CamScanner

ស្អាង ខេត្តកណ្ដាល នៅលីវ ឪពុកឈ្មោះ [redacted] សារិទ្ធ " រស់" ម្ដាយឈ្មោះ [redacted] ពេញ "ស្លាប់" ។ (ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២៥០ ដក.ប.ច.ខ/២២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល) ។

ជាប់ចោទពីបទ:អំពើលួច ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី១៩ខែមីនា ឆ្នាំ ២០២២ តាមមាត្រា ៣៥៣ និង មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

- មេធាវីលោក [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ១៦ ឆ្នាំ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធា ភេទប្រុស អាយុ ៣៦ ឆ្នាំ មានទីលំនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ។

-បានឃើញ របាយការណ៍បញ្ជាក់រឿងហេតុលេខ: ០០៣/ ២២ របក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ របស់នាយប៉ុស្តិ៍នគរបាលកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ។

-បានឃើញដី កាសន្និដ្ឋានស្ដាពរលេខ ៥០៧ ដកសព/២២ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥២៧ ដកដស/២២ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរ នៃ សាលាដំបូងខេត្តកណ្ដាល។

## អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីអំឡុងឆ្នាំ ២០២១ មានជនសង្ស័យឈ្មោះ [redacted] សំណាង ធ្លាប់ប្រព្រឹត្តសកម្មភាពលួចចំនួន៥លើកហើយដោយលួចផ្លែត្រយូងចេកក្នុងចំការគេ ។ លុះដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ ម៉ោង៤ ជិតភ្លឺ ជនសង្ស័យឈ្មោះ [redacted] សារ៉ែន .ឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] លាងហ៊ីម ធ្វើសកម្មភាពលួចមាន់ជនរងគ្រោះឈ្មោះ [redacted] ប៊ុនធា នៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល បានសម្រេច ។ បន្ទាប់មកឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] លាងហ៊ីម ចូលប្រាក់គ្នាទិញមាន់១ក្បាលពីឈ្មោះ [redacted] សារ៉ែន ក្នុងតំលៃ ៣ម៉ឺនរៀលយកទៅលក់ឱ្យជនមិនស្គាល់ឈ្មោះនៅម្ដុំឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល រហូតដល់ម៉ោង៨.៣០នាទី ជនសង្ស័យឈ្មោះ [redacted] សំណាង និង ឈ្មោះ [redacted] លាងហ៊ីម ត្រូវសមត្ថកិច្ចឃាត់ខ្លួនបញ្ជូនអធិការដ្ឋាននគរបាលស្រុកស្អាងធ្វើតេស្តទឹកនោមលទ្ធផលវិជ្ជមាន ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] សំណាង បានឆ្លើយពេលសវនាការថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] សារ៉ែន បានយកម៉ាន់ដល់លក់ឱ្យខ្លួនតំលៃ ៣ ម៉ឺនរៀល ហើយមាន់នេះខ្លួនមិនដឹងថា [redacted] សារ៉ែន បានមកពីណាទេ ។ មាន់នេះខ្លួនលក់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] សារ៉ែន ស្គាល់យូរហើយ ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនយូរឆ្នាំហើយ ។ នៅក្នុង១អាទិត្យប្រើប្រាស់គ្រឿងញៀន២ដង ។ ឈ្មោះ [redacted] សារ៉ែន ជាអ្នកលួច ហើយពួកខ្លួនជាអ្នកលក់ ។

-ជនជាប់ចោទឈ្មោះ [redacted] លាងហ៊ីម បានឆ្លើយពេលសវនាការថា ឈ្មោះ [redacted] សារ៉ែន ជាអ្នកលួច ហើយឱ្យខ្លួនយកទៅលក់ ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនយូរហើយ។



Scanned with CamScanner

-ក្រឡាបញ្ជីអានពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធា ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២២ ប្តឹងពីឈ្មោះ[redacted] សំណាង ភេទប្រុស អាយុ ១៧ ឆ្នាំ និងឈ្មោះ [redacted] លាងហ៊ីម ភេទប្រុស អាយុ ២២ ឆ្នាំ និងឈ្មោះ[redacted]រ៉េន ពីអំពើលួច ដោយកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ៨.៣០ នាទីព្រឹកអ្នកទាំងបីបានលួចម៉ាន់ខ្លួនទៅលក់នៅឃុំព្រែកអំពិល ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទទាំង២នាក់នេះពិតជាបានសមគំនិតក្នុងអំពើលួច និងប្រើប្រាស់គ្រឿងញៀន។ រីឯឈ្មោះ [redacted] សារ៉េន ជាអ្នកលួច ។ ជនជាប់ចោទទាំង២នាក់ទទួលស្គាល់នូវបទចោទប្រកាន់របស់តំណាងអយ្យការ ។ ដូច្នេះ តំណាងអយ្យការស្នើសុំតំកល់ដីកាដំណោះស្រាយទុកដដែល ជូនតុលាការសម្រេចតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] សំណាង ធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនទទួលស្គាល់បទចោទស្នើសុំសំរាលទោស ។

+ជនជាប់ចោទឈ្មោះ [redacted] សំណាង និយាយសំដីចុងក្រោយ សុំឲ្យតុលាការជួយបន្ធូរបន្ថយ

+ជនជាប់ចោទឈ្មោះ [redacted] លាងហ៊ីម និយាយសំដីចុងក្រោយ សុំឲ្យតុលាការជួយបន្ធូរបន្ថយ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាង

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១- តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោះ[redacted] សំណាង ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិខ្មែរ.ជនជាប់ចោទឈ្មោះ[redacted] លាងហ៊ីម ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ ពីបទៈសមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ [redacted] សារ៉េន ភេទប្រុស អាយុ ១៨ ឆ្នាំ ជនជាតិខ្មែរ ពីបទៈ អំពើលួច តាមដីកាដំណោះស្រាយ លេខលេខ ៥២៧ ដកដស /២២ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០២២ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទ យោងតាមមាត្រា ២៨៩ ,២៩១ មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- ផ្អែកតាមរបាយការណ៍របស់សមត្ថកិច្ច,ចំលើយជនជាប់ចោទ ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សំណាង និងជនជាប់ចោទឈ្មោះ[redacted] លាងហ៊ីម នៅថ្ងៃកើតហេតុពិតជាបាន

ចូលលុយគ្នាទៅទិញមាន់ជលពីឈ្មោះ [redacted] សារ៉េន ដែលបានលួចពីម្ចាស់មាន់ឈ្មោះ [redacted] ប៊ុនធា ពិតមែន ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] លាងហ៊ីម គឺ ជាអង្គហេតុត្រូវនឹងបទល្មើស សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមមាត្រា ២៩ មាត្រា ៣៥៣ មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌនិង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សារ៉េន ដែលបានលួចមាន់ពីម្ចាស់ឈ្មោះ [redacted] ប៊ុនធា ពិតមែន ហើយបានគេចខ្លួនបាត់ ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន គឺជាអង្គហេតុត្រូវបទល្មើសៈអំពើលួច ដែលមានចែងតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣- ជនជាប់ចោទឈ្មោះ [redacted] សំណាង ,ឈ្មោះ [redacted] លាងហ៊ីម និងឈ្មោះ [redacted] សារ៉េន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន ។

៤- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] លាងហ៊ីម ពីបទៈ សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ពីបទៈអំពើលួច ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥- មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ៖

ក-ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ១៦ ឆ្នាំ និងឈ្មោះ [redacted] លាងហ៊ីម ភេទប្រុស អាយុ ២២ ឆ្នាំ ពីបទៈ សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា ២៩,មាត្រា ៣៥៣ មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ឈ្មោះ [redacted] សារ៉េន ភេទប្រុស អាយុ ១៨ ឆ្នាំ ពីបទៈ អំពើលួច ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៦- អំពើដែលជនជាប់ចោទឈ្មោះ [redacted] សំណាង,ឈ្មោះ [redacted] លាងហ៊ីម និងឈ្មោះ [redacted] សារ៉េន បានប្រព្រឹត្តបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និង សន្តិសុខសង្គម ព្រមទាំងធ្វើឲ្យបាត់បង់ទ្រព្យអ្នកដទៃ ។ ក៏ប៉ុន្តែ ជនជាប់ចោទឈ្មោះ [redacted] សំណាង ជាអនីតិជន ហើយអ្នកលួចមាន់ដល់ផ្ទាល់គឺឈ្មោះ [redacted] សារ៉េន ដូច្នេះទណ្ឌកម្មដែលត្រូវអនុវត្តលើជនជាប់ចោទនីមួយៗតុលាការនឹងពិចារណា ។

៧- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធា ពុំបានទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទទេ ដូច្នេះចំណុចនេះតុលាការមិនលើកមកពិនិត្យសម្រេចឡើយ ។

៨. ជនជាប់ចោទឈ្មោះ [redacted] សារ៉េន នៅថ្ងៃកើតហេតុបានគេចខ្លួន ដូច្នេះ ដើម្បីធានាការអនុវត្តច្បាប់ គប្បីចេញដីកាបង្គាប់ឲ្យចាប់ខ្លួន យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

១- ផ្តន្ទាទោស៖



Scanned with CamScanner

ក/ ឈ្មោះ [redacted] សារ៉េន ភេទប្រុស អាយុ ១៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ១ (មួយ) ឆ្នាំ ពីបទ: អំពើលួច ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ តាមមាត្រា ៣៥៣ ,មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

ខ/ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ១៦ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ៦ (ប្រាំមួយ)ខែ ពីបទ: សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ តាមមាត្រា ២៩,មាត្រា៣៥៣ មាត្រា៣៥៦មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

គ/ឈ្មោះ [redacted] ណាងហ៊ីម ភេទប្រុស អាយុ ២២ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ៨ (ប្រាំបី)ខែ ពីបទ: សមគំនិតក្នុងអំពើលួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២២ តាមមាត្រា ២៩,មាត្រា៣៥៣ មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២- បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សារ៉េន យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និង ប្រកាសនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២២ ចំពោះមុខ ជនជាប់ចោទឈ្មោះ [redacted] សំណាង .ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណាងហ៊ីម .ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉េន និង កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធា រក្សាសិទ្ធិប្ដឹងទាស់ ឬ ប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខាត្រា [redacted]

---

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក.ព.ស ២៥៦៦

កណ្ដាល , ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]